1-877-328-9677




## របៀបប្រើប័ណ្ណ EBT របស់លោកអ្នកដើម្បីទិញទំនិញ

នៅមុនពេលលោកអ្នកទិញទំនិញ សូមឆែកមើលចំនួនប្រាក់ដែលនៅសល់ក្រោយពីការចំណាយដោយមើលបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ទូរស័ព្ទទៅផ្នែកបំរើអតិថិជនតាមលេខឥតបង់ប្រាក់ 1-877-328-9677 ឬតាមប្រព័ន្ធអ៊ីនធឺណិត www.ebt.ca.gov ។ ចំនួនដែលនៅសល់នេះ គឺជាចំនួនច្រើនបំផុតដែលអាចចំណាយជាមួយប័ណ្ណរបស់លោកអ្នក។

**ជំហានទី1** ជ្រើសរើសទំនិញម្ហូបអាហាររបស់លោកអ្នក ហើយនាំទៅកាន់ផ្លូវគិតប្រាក់ ។ អាស្រ័យទៅលើហាងទំនិញ លោកអ្នកអាចត្រូវបែងចែកទំនិញជាម្ហូបដែលមានសិទ្ធិទិញដោយឡែកពីមុខរបស់ដែលលោកអ្នកមិនមានសិទ្ធិទិញ ។ សូមប្រាប់អ្នកគិតប្រាក់ថាលោកអ្នកចង់ប្រើ"ប័ណ្ណទិញម្ហូប" ឬក៏"ប្រាក់ជំនួយ" ។ លោកអ្នកអាចប្រើជំនួយទាំងពីរ ប៉ុន្តែលោកអ្នកត្រូវឆូតប័ណ្ណរបស់លោកអ្នកសំរាប់ការទិញនីមួយៗនេះផ្សេងពីគ្នា ។

**ជំហានទី2** ឆូតប័ណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬ ហុចប័ណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នកទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ "ENTER" ។ បើសិនជាលោកអ្នកប្រើប្រាក់ជំនួយហើយលោកអ្នកចង់ដកយកប្រាក់ជាបន្ថែមលើថ្លៃទិញ សូមប្រាប់អ្នកគិតប្រាក់អំពីចំនួនដែលលោកអ្នកចង់ដក ។

**ជំហានទី5** អ្នកគិតប្រាក់ចុចបញ្ចូលចំនួនតម្លៃជាប័ណ្ណទិញម្ហូប ឬប្រាក់ជំនួយ ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ "OK" ឬពាក្យ "YES" ។

**ជំហានទី6** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់ សំរាប់ការទិញនីមួយៗ ដែលមានបង្ហាញ:
- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនប្រាក់ដែលលោកអ្នកបានទិញ
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយរបស់លោកអ្នក

**ជំហានទី7** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយសំរាប់លោកអ្នកទៅទិញទំនិញនៅពេលក្រោយ ។

**សូមចងចាំថា គេមិនអាចគិតថ្លៃឈ្នួលសំរាប់ការប្រើជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក និងលោកអ្នកមិនអាចដកយកប្រាក់ ឬលុយអាប់មកវិញពី គណនីជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នកឡើយ ។**

## របៀបប្រើប័ណ្ណ EBT របស់លោកអ្នកនៅតាមម៉ាស៊ីន ATM

**ជំហានទី1** ស៊កឬឆូតប័ណ្ណរបស់លោកអ្នកទៅក្នុងម៉ាស៊ីន ATM ។

**ជំហានទី2** ចុចបញ្ចូលលេខសម្ងាត់ PIN ដែលមានបួនលេខរបស់លោកអ្នកនៅលើបន្ទះចុចលេខ រួចចុចពាក្យ "OK" ឬពាក្យ "ENTER" ។

**ជំហានទី3** ជ្រើសរើសពាក្យដកយកប្រាក់ "WITHDRAW CASH" រួចមកជ្រើសរើសពាក្យគណនីសែក "CHECKING" ។ (ម៉ាស៊ីន ATM ខ្លះប្រើពាក្យផ្សេងពីនេះ) ។

**ជំហានទី4** សូមចុចយកចំនួនប្រាក់ដុល្លារដែលលោកអ្នកចង់ដក ជាចំនួនប្រាក់ដុំ (ជាឧទាហរណ៍ ចំនួន $20 ឬ $200 ឬចំនួនឯទៀត) ។ សន្លឹកប្រាក់១០ដុល្លារ និង២០ដុល្លារ ជាសន្លឹកប្រាក់តូចជាងគេដែលធម្មតាគេបានប្រើ ។

**ជំហានទី5** ម៉ាស៊ីន ATM នឹងបង្ហាញនៅលើកញ្ចក់ប្រាប់លោកអ្នកអំពីចំនួនថ្លៃឈ្នួល ។ បើសិនជាលោកអ្នកយល់ព្រម សូមចុចពាក្យបន្ត "CONTINUE"។ បើសិនជាលោកអ្នកមិនចង់បង់ថ្លៃឈ្នួលទេ លោកអ្នកអាចចុចពាក្យលុបចោល "CANCEL" ។

**ជំហានទី6** ម៉ាស៊ីន ATM នឹងផ្តល់ប្រាក់និងបង្កាន់ដៃជូនលោកអ្នក ។ ម៉ាស៊ីន ATM ខ្លះមិនមានបោះពុម្ពនៅលើបង្កាន់ដៃនូវចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយរបស់លោកអ្នកឡើយ ។

**ជំហានទី7** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយរបស់លោកអ្នក ។

## របៀបប្រើបណ្ណ EBT របស់លោកអ្នកដើម្បីដកយកប្រាក់ នៅតាមម៉ាស៊ីន Point-of-Sale (POS)

**ជំហានទី1** សូមសាកសួរអ្នកគិតប្រាក់នៃហាងទំនិញថាតើលោកអ្នកអាចដកយកប្រាក់ជំនួយនៅហាងនោះ និងតើគេគិតថ្លៃឈ្នួលឬទេ ។

**ជំហានទី2** ឆូតបណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីនចំណុចលក់ទំនិញ (POS) ឬហុចបណ្ណ EBT របស់លោកអ្នកទៅឱ្យអ្នកគិតប្រាក់ ។

**ជំហានទី3** ចុចបញ្ចូលលេខសម្ងាត់ (PIN) បួនខ្ទង់របស់លោកអ្នកទៅលើបន្ទះលេខចុច ។ ម៉ាស៊ីននឹងបង្ហាញសញ្ញា **** ជាជំនួសលេខដែលលោកអ្នកចុច ។

**ជំហានទី4** សូមចុចពាក្យ "ENTER" ។

**ជំហានទី5** ប្រាប់អ្នកគិតប្រាក់អំពីចំនួនប្រាក់ដែលលោកអ្នកចង់បាន ។

**ជំហានទី6** អ្នកគិតប្រាក់ចុចបញ្ចូលចំនួននៃប្រាក់ជំនួយដែលត្រូវដកយកពីគណនីរបស់លោកអ្នក ។ បើសិនជាចំនួនទឹកប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ "OK" ឬពាក្យ "YES" ។

**ជំហានទី7** លោកអ្នកនឹងទទួលសំណៅបង្កាន់ដៃបោះពុម្ពមួយច្បាប់បង្ហាញ:
- ឈ្មោះនិងអាសយដ្ឋានហាងទំនិញ
- ចំនួនទិញជាប្រាក់ដែលលោកអ្នកបានដកយក
- ចំនួនថ្មីនៅសល់បន្ទាប់ពីចំណាយនៃគណនីប្រាក់ជំនួយរបស់លោកអ្នក

**ជំហានទី8** សូមរក្សាទុកបង្កាន់ដៃរបស់លោកអ្នក ដើម្បីលោកអ្នកអាចដឹងចំនួននៅសល់ថ្មីបន្ទាប់ពីចំណាយរបស់លោកអ្នក ។

## របៀបឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយ នៃបណ្ណ EBT របស់លោកអ្នក

ចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយថ្មីរបស់លោកអ្នក ត្រូវបានបោះពុម្ពនៅលើបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ។ **សូមរក្សាទុកបង្កាន់ដៃ របស់លោកអ្នកជានិច្ច** ។ បើសិនជាលោកអ្នកធ្វើបាត់បង្កាន់ដៃចុងក្រោយរបស់លោកអ្នក លោកអ្នកអាចទូរស័ព្ទទៅផ្នែកបំរើអតិថិជន ឆែកមើលចំនួនប្រាក់នៅសល់បន្ទាប់ពីចំណាយនៅម៉ាស៊ីន ATM ឬ POS ឬតាមប្រព័ន្ធអ៊ិនធឺណិត www.ebt.ca.gov ។ លោកអ្នកនឹងត្រូវបង់ថ្លៃឈ្នួល 25 សេន បើសិនជាលោកអ្នកឆែកមើលចំនួននៅសល់តាមមាស៊ីន ATM ។
បើសិនជាលោកអ្នកបាត់បណ្ណ ឬក៏បណ្ណត្រូវគេលួច សូមទូរស័ព្ទទៅ ផ្នែកបំរើអតិថិជនជាបន្ទាន់តាមលេខ 1-877-328-9677 ។ ពួកគេនឹងជំរាបលោកអ្នកអំពីរបៀបទទួលបណ្ណ ថ្មី ។ បើសិនជាលោកអ្នកមិនបានរាយការណ៍ថាបណ្ណរបស់លោកអ្នកបានបាត់ ឬចោរលួចទេ អ្នកណាម្នាក់អាចប្រើបណ្ណនិងចំណាយប្រាក់របស់លោកអ្នកទាំងអស់ហើយ ជំនួយទាំងនេះនឹងមិនត្រូវបានផ្តល់ជូនលោកអ្នក វិញទេ ។

## សូមទូរស័ព្ទផ្នែកបំរើអតិថិជនតាមលេខឥតបង់ប្រាក់ បើសិនជា:

- លោកអ្នកបាត់បណ្ណ ឬត្រូវគេលួចបណ្ណរបស់លោកអ្នក ។
- បណ្ណរបស់លោកអ្នកខូច ប្រើការលែងកើត ។
- លោកអ្នកមានបំណងចង់ប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ពីព្រោះលោកអ្នកភ្លេចលេខ ឬមាននរណាម្នាក់ដឹងលេខសម្ងាត់ PIN របស់លោកអ្នក ។ ការិយាល័យផ្តល់ជំនួយសារធារណៈរបស់លោកអ្នកអាចជួយប្តូរលេខសម្ងាត់ PIN របស់លោកអ្នកបាន ។
- លោកអ្នកមានបំណងចង់ដឹងអំពីចំនួនប្រាក់ ដែលនៅសល់ក្នុងគណនីរបស់លោកអ្នក ។
- លោកអ្នកត្រូវបានគេគិតប្រាក់ថ្លៃទិញប៉ុន្តែលោកអ្នកមិនបានទទួលទំនិញ ឬក៏គេគិតប្រាក់លោកអ្នក លើសពីចំនួនតម្លៃដែលលោកអ្នកបាន ទិញ ។
- លោកអ្នកមានសំណួរ ឬបញ្ហាផ្សេងទៀត ។

**ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍**

**1-877-328-9677**

**TTY: 1-800-735-2929 (ប្រព័ន្ធទូរស័ព្ទបញ្ជូនបន្ត សំរាប់លោកអ្នកដែលមានភាពពិការក្នុងការស្តាប់និងការនិយាយ)**

សូមមើលតារាងនៅក្នុងកូនសៀវភៅណែនាំ EBT របស់លោកអ្នក និងសរសេរថ្ងៃដែលគេនឹងដាក់បញ្ចូលជំនួយទៅក្នុងគណនីរបស់លោកអ្នក :

__________________________________________

ជំនួយបណ្ណទិញម្ហូប (ថ្ងៃទី១ ទៅដល់ថ្ងៃទី១០នៃខែ)

__________________________________________

ប្រាក់ជំនួយ (ថ្ងៃទី១, ទី២ ឬទី៣នៃខែ)

USDA គឺជាក្រសួងផ្តល់កិច្ចជួយនិងការងារស្មើៗគ្នា ។

STATE OF CALIFORNIA
HEALTH AND HUMAN SERVICES AGENCY
DEPARTMENT OF SOCIAL SERVICES

PUB 389 (Cambodian) (5/09)